**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
Ministry of Industry, Science, Technology & Innovation

លេខ: ១៣៨០១៧.៥...ឧវបន...ចរក...សជណា.

ថ្ងៃចន្ទ ៦កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការលើកទឹកចិត្តក្នុងការស្នើសុំអាជ្ញាបណ្ណប្រើសញ្ញាចុះបញ្ជីផលិតផល (ច.ប.ផ.)

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សូមជូនដំណឹងដល់ក្រុមហ៊ុនផលិត ក្រុមហ៊ុននាំចូលទំនិញ និងធុរជនទាំងអស់ ជ្រាបថា៖ ដើម្បីលើកទឹកចិត្ត និងសម្រួលដល់ដំណើរការស្នើសុំអាជ្ញាបណ្ណប្រើសញ្ញាចុះបញ្ជីផលិតផល (ច.ប.ផ.) ក្រសួងបានរៀបចំយុទ្ធនាការផ្សព្វផ្សាយជំរុញការស្នើសុំអាជ្ញាបណ្ណ ច.ប.ផ. ដល់ក្រុមហ៊ុនផលិត ក្រុមហ៊ុននាំចូលទំនិញ និងធុរជន **ដែលនឹងចាប់ផ្តើមអនុវត្តពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៥ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៦**។ ក្រសួងមានវិទ្យាស្ថានស្តង់ដាកម្ពុជា ជាសេនាធិការ បានកែសម្រួល និងរៀបចំផ្តល់កញ្ចប់លើកទឹកចិត្តដូចខាងក្រោម៖

ក. ឯកសារតម្រូវ សម្រាប់ផលិតផលផលិតក្នុងស្រុក (ថតចម្លង)
១. ឯកសារក្រុមហ៊ុន (ប៉ាតង់ដែលមានសុពលភាព) និងវិញ្ញាបនបត្រដំណើរការរោងចក្រ សហគ្រាស សិប្បកម្ម សម្រាប់ការស្នើសុំលើកដំបូង
២. គំរូស្លាកសញ្ញាផលិតផលអនុលោមតាម CS001-2000 (ពណ៌ធម្មជាតិ ១ច្បាប់)
៣. វិញ្ញាបនបត្រវិភាគផលិតផល (មានសុពលភាពចាប់ពីថ្ងៃចេញលទ្ធផលយ៉ាងយូរ ៦ខែ)

ខ. ឯកសារតម្រូវ សម្រាប់ផលិតផលនាំចូល (ថតចម្លង)
១. ឯកសារក្រុមហ៊ុន(ប៉ាតង់ដែលមានសុពលភាព)
២. គំរូស្លាកសញ្ញាផលិតផលអនុលោមតាម CS001-2000 (ពណ៌ធម្មជាតិ ១ច្បាប់)
៣. វិញ្ញាបនបត្របញ្ជាក់ផលិតផល ឬវិញ្ញាបនបត្រវិភាគផលិតផល
(មានសុពលភាពចាប់ពីថ្ងៃចេញលទ្ធផលយ៉ាងយូរ៦ខែ)
៤. សិទ្ធិនាំចូលចែកចាយផ្តាច់មុខ ឬលិខិតដែលមានតម្លៃស្មើ ឬលិខិតធានាអះអាងគុណភាព

**គ. ការបង្កើតម្រៃសេវាសាធារណៈ៖**
ចំពោះការស្នើសុំជាកញ្ចប់ កម្រៃសេវាសាធារណៈសម្រាប់ការស្នើសុំអាជ្ញាបណ្ណ (ច.ប.ផ.) ក្នុងមួយមុខផលិតផលដែលកន្លងមកមានតម្លៃ ២០០.០០០រៀល នឹងត្រូវអនុវត្តដូចខាងក្រោម៖
១. បញ្ចុះតម្លៃ ១០% រាល់ការស្នើសុំ ច.ប.ផ. ចាប់ពី៥ ដល់ ១៩ មុខផលិតផល ក្នុងពេលតែមួយ
២. បញ្ចុះតម្លៃ ១៥% រាល់ការស្នើសុំ ច.ប.ផ. ចាប់ពី២០ ដល់ ៤៩ មុខផលិតផល ក្នុងពេលតែមួយ
៣. បញ្ចុះតម្លៃ ២០% រាល់ការស្នើសុំ ច.ប.ផ. ចាប់ពី៥០ មុខផលិតផលឡើងទៅ ក្នុងពេលតែមួយ

ឃ. ផលិតផលដែលទទួលបានវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមផលិតផល (CS) រួចហើយ មិនតម្រូវឱ្យស្នើសុំអាជ្ញាបណ្ណ (ច.ប.ផ.) ទៀតទេ។

ង. ផលិតផលដែលទទួលបានវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមផលិតផល (CS) ឬអាជ្ញាបណ្ណ (ច.ប.ផ.) រួចហើយ ពុំចាំបាច់ស្នើសុំបន្ថែមនូវសញ្ញាផលិតផលកម្ពុជាមានគុណភាពទេ។

ច. អ្នកដាក់ពាក្យស្នើសុំអាចយកសំណាកផលិតផលទៅវិភាគដោយខ្លួនឯងនៅមន្ទីរពិសោធន៍ដែលមានការវាយតម្លៃទទួលស្គាល់។

ឆ. អ្នកដាក់ពាក្យអាចស្នើសុំការប្រឹក្សាយោបល់ ឬព័ត៌មានបន្ថែម ពីក្រុមការងារពិសេស នៃវិទ្យាស្ថានស្តង់ដារកម្ពុជា តាមរយៈលេខទូរសព្ទ ឬតេឡេក្រាម៖ ០៨១ ៩៨៩ ៤៥០។

រដ្ឋមន្ត្រី

ហែម វណ្ណឌី